**ព្រះរាជាណាចក្រកម្ពុជា**
ជាតិ សាសនា ព្រះមហាក្សត្រ

**ក្រសួងមុខងារសាធារណៈ**

# លិខិតជូនពរ

**សូមគោរពជូន**
**សម្តេចកិត្តិព្រឹទ្ធបណ្ឌិត ប៊ុន រ៉ានី ហ៊ុន សែន ប្រធានកាកបាទក្រហមកម្ពុជា**
**ក្នុងឱកាសទិវានារីអន្តរជាតិ ៨ មីនា ឆ្នាំ២០២៣**

***សម្តេចកិត្តិព្រឹទ្ធបណ្ឌិត ជាទីគោរពដ៏ខ្ពង់ខ្ពស់***

ក្នុងឱកាសខួបអនុស្សាវរីយ៍លើកទី១១២ នៃទិវានារីអន្តរជាតិ ៨ មីនា ឆ្នាំ២០២៣ យើងខ្ញុំទាំងអស់គ្នាជាថ្នាក់ដឹកនាំ និងមន្ត្រីរាជការ នៃក្រសួងមុខងារសាធារណៈ សូមចូលរួមអបអរសាទរដោយសេចក្តីសោមនស្សរីករាយក្រៃលែង និងសូមបួងសួងដល់គុណបុណ្យព្រះរតនត្រ័យ និងវត្ថុស័ក្តិសិទ្ធិទាំងអស់ក្នុងលោក សូមជួយប្រោះព្រំសព្ទសាធុការពរ សិរីសួស្តី ជ័យមង្គល វិបុលសុខ បវរមហាប្រសើរជូន **សម្តេចកិត្តិព្រឹទ្ធបណ្ឌិត ប៊ុន រ៉ានី ហ៊ុន សែន** ប្រធានកាកបាទក្រហមកម្ពុជា សូម **សម្តេច** ទទួលបានសុខភាពល្អបរិបូរណ៍ បញ្ញាញាណវាងវៃ ជ័យជំនះគ្រប់ប្រការ និងវៀរចាកផុតពីរោគាព្យាធិគ្រប់ពេលវេលា ដើម្បីបន្តដឹកនាំស្ថាប័នកាកបាទក្រហមកម្ពុជាឱ្យកាន់តែរីកចម្រើនបន្ថែមទៀត។

ក្នុងឱកាសនៃទិវានារីអន្តរជាតិដ៏ថ្លៃថ្លា និងមានអត្ថន័យនេះ យើងខ្ញុំទាំងអស់គ្នា សូមកោតសរសើរ **សម្តេចកិត្តិព្រឹទ្ធបណ្ឌិត** ដោយស្មោះអស់ពីដួងចិត្ត ដែលជាកុលធីតាខ្មែរដ៏ឆ្នើមមួយរូប ចំពោះស្នាដៃប៉ិនប្រសប់ និងធំធេងក្នុងកិច្ចការបម្រើជាតិ និងប្រជាជនខ្មែរ ដោយបានយកអស់នូវកម្លាំងកាយចិត្ត ប្រាជ្ញា ស្មារតី និងពលិកម្មគ្រប់បែបយ៉ាងក្នុងការដឹកនាំស្ថាប័នកាកបាទក្រហមកម្ពុជា ដើម្បីការងារមនុស្សធម៌ដ៏ថ្លៃថ្លា ប្រកបដោយគុណធម៌ និងសប្បុរសធម៌ ជួយដោះស្រាយទុក្ខលំបាករបស់ប្រជាជន គ្រប់កាលៈទេសៈ និងគ្រប់ទីកន្លែង។ ជាពិសេស **សម្តេច** បានខិតខំលើកកម្ពស់តម្លៃសីលធម៌សង្គមខ្មែរ តម្លៃនិងសិទ្ធិស្ត្រី និងគ្រួសារខ្មែរបានខ្ពង់ខ្ពស់និងរុងរឿង។ ទាំងនេះបង្ហាញឱ្យឃើញយ៉ាងប្រត្យក្សថា **សម្តេច** គឺជាស្ត្រីខ្មែរដ៏ឆ្នើមមួយរូប ដែលជាភរិយានិងជាមាតាដ៏ប្រសើរឧត្តម និងជាគំរូដល់ស្ត្រីខ្មែរនិងគ្រួសារខ្មែរទូទៅ។

យើងខ្ញុំទាំងអស់គ្នា សូមបួងសួងដល់គុណបុណ្យព្រះរតនត្រ័យ និងវត្ថុស័ក្តិសិទ្ធិទាំងអស់ក្នុងលោក សូម **សម្តេចកិត្តិព្រឹទ្ធបណ្ឌិត** និង **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា** ព្រមទាំង **បុត្រា បុត្រី ចៅប្រុស ចៅស្រី** សូមមានសុខភាពល្អបរិបូរណ៍ និងសមប្រកបនូវព្រះពុទ្ធពរទាំងបួនប្រការគឺ អាយុ វណ្ណៈ សុខៈ និងពលៈ កុំបីឃ្លៀងឃ្លាតឡើយ។

សូម **សម្តេចកិត្តិព្រឹទ្ធបណ្ឌិត ប្រធានកាកបាទក្រហមកម្ពុជា** មេត្តាទទួលនូវគារវកិច្ចដ៏ខ្ពង់ខ្ពស់ពីយើងខ្ញុំទាំងអស់គ្នា។

ថ្ងៃ សុក្រ ១២កើត ខែ ផល្គុន ឆ្នាំខាល ចត្វាស័ក ព.ស.២៥៦៦
រាជធានីភ្នំពេញ ថ្ងៃទី០៣ ខែ មីនា ឆ្នាំ២០២៣
**តំណាងថ្នាក់ដឹកនាំនិងមន្ត្រីរាជការនៃក្រសួងមុខងារសាធារណៈ**
**រដ្ឋមន្ត្រី**

**ព្រុំ សុខា**

ផ្លូវវត្តអង្គតាម៉ិញ ភូមិគោកចំបក់ សង្កាត់ចោមចៅ ខណ្ឌពោធិ៍សែនជ័យ រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
ទូរស័ព្ទ/ទូរសារ : +៨៥៥-២៣-៨៦៦៥០១/+៨៥៥-២៣-៨៦៦៥០៥ | គេហទំព័រ : http://www.mcs.gov.kh